ក្រុមប្រឹក្សាគណបក្សខេត្តបាត់ដំបង
ចលនាយុវជនខេត្តបាត់ដំបង

# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## សេចក្តីអំពាវនាវ

**ចលនាយុវជន សម រង្ស៊ី ខេត្តបាត់ដំបង** សូមជំរាបជូន សមាជិក សមាជិកា និងថ្នាក់ដឹកនាំ **គណបក្ស សម រង្ស៊ី** ព្រមទាំងអ្នកប្រជាធិបតេយ្យទាំងក្នុងប្រទេស និងក្រៅប្រទេស ឱ្យបានជ្រាបថា **ចលនាយុវជន សម រង្ស៊ី** ខេត្តបាត់ដំបង បាន និងកំពុងដំណើរការសកម្មភាពរបស់ខ្លួន ក្នុងនោះរួមមានទាំងការពង្រឹង និងបណ្តុះបណ្តាលសមាជិករបស់ខ្លួនដើម្បីឱ្យក្លាយជាសសរទ្រូងប្រទេសជាតិ និងក្លាយទៅជាមេដឹកនាំនាពេលអនាគត។

ជាលទ្ធផល ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ខាងមុខនេះ **ចលនាយុវជន សម រង្ស៊ី ខេត្តបាត់ដំបង** មានសមាជិក និងថ្នាក់ដឹកនាំមួយចំនួនដែលនឹងត្រូវចូលរួមក្នុងការបោះឆ្នោតនេះផងដែរ។ ហើយពួកគេទាំងនោះនឹងក្លាយទៅជាអ្នកដឹកនាំនាពេលដ៏ខ្លីខាងមុខ ពោលគឺនឹងក្លាយទៅជាក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក។

ដូច្នេះដើម្បីជាទុន និងដើម្បីជំរុញឱ្យយុវជនទាំងនោះក្លាយទៅជាអ្នកដឹកនាំពិតប្រាកដ ក្នុងគោលបំណងពង្រីក និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា **ចលនាយុវជន សម រង្ស៊ី ខេត្តបាត់ដំបង** មានផែនការដូចតទៅ :

-រៀបចំវគ្គបណ្តុះបណ្តាលដល់ជាយុវជន នូវកម្មវិធី "**ភាពជាអ្នកដឹកនាំ**" ជាពិសេសបេក្ខជន

-ទំនាក់ទំនងជាមួយអ្នកបោះឆ្នោត (សូមបញ្ជាក់ថា ការបោះឆ្នោតនេះគឺជាការបោះឆ្នោតអសកល អង្គបោះឆ្នោតគឺជាសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងតំណែង)

ដោយជួបប្រទះនឹងកង្វះខាតថវិកា ជួសមុខឱ្យ **ចលនាយុវជន សម រង្ស៊ី ខេត្តបាត់ដំបង** ខ្ញុំសូមអំពាវនាវដល់ សមាជិក សមាជិកា និងថ្នាក់ដឹកនាំ **គណបក្ស សម រង្ស៊ី** ព្រមទាំង អ្នកប្រជាធិបតេយ្យទាំងក្នុងប្រទេស និងក្រៅប្រទេស មេត្តាជួយឧបត្ថម្ភជាសំភារះ ឯកសារ រឺ ថវិកាតាមសមានចិត្ត និងលទ្ធភាព ដើម្បីចូលរួមចំណែកក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនចំពោះទឹកចិត្តដ៏សប្បុរសរបស់អស់លោក-លោកស្រី-នាងកញ្ញា។

បាត់ដំបង, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩

**ជ.ចលនាយុវជនខេត្តបាត់ដំបង**

**ប្រធាន**

**សួន ចំរើន**

*សូមភ្ជាប់មកជាមួយ* :

*-បញ្ជីឈ្មោះយុវជន ជាបេក្ខជន*

*✱ទំនាក់ទំនង* :

*ទូរស័ព្ទដៃ : (855)12 644 484*
*E-mail : schknym1@yahoo.com*

ក្រុមប្រឹក្សាគណបក្សខេត្តបាត់ដំបង
ចលនាយុវជនខេត្តបាត់ដំបង

# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## បញ្ជីឈ្មោះ

**ថ្នាក់ដឹកនាំ សមាជិក សមាជិកា ចលនាយុវជន សម រង្ស៊ី ក្នុងខេត្តបាត់ដំបង ឈរឈ្មោះជាបេក្ខជន ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (លំដាប់លេខរៀងអាទិភាព)**

| ល.រ | នាម_គោត្តនាម | ភេទ | ថ្ងៃ_ខែ_ឆ្នាំកំណើត | តួនាទី | ទីតាំង | ទីតាំងឈរឈ្មោះ | ល.រ.ឈរ | ចំនួនរំពឹងជាប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | ជា ជីវ | ប្រុស | ១១-០៦-៨១ | គណៈកម្មាធិការនាយក-យុវជន | ខេត្តបាត់ដំបង | ខេត្តបាត់ដំបង | ៣ | ៥ | |
| ២ | អន ចន្ថា | ប្រុស | ០៦-០៦-៨០ | ប្រធានចលនាយុវជនស្រុក | ស្រុកបាណន់ | ស្រុកបាណន់ | ៣ | ៥ | |
| ៣ | ស៊ុន កុសល | ប្រុស | ១០-០៩-៨០ | ប្រធានចលនាយុវជនស្រុក | ស្រុកបាត់ដំបង | ក្រុងបាត់ដំបង | ៣ | ៥ | |
| ៤ | ផាន់ ដារ៉ា | ប្រុស | ០៩-១២-៧៧ | សមាជិកចលនាយុវជនស្រុក | ស្រុកបាត់ដំបង | ក្រុងបាត់ដំបង | ៥ | ៥ | |
| ៥ | ឆម ហ៊ា | ប្រុស | ០២-១២-៨២ | អនុប្រធានចលនាយុវជនខេត្ត | ខេត្តបាត់ដំបង | ស្រុកឯកភ្នំ | ២ | ៤ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦ | នេត សារិទ្ធ | ប្រុស | ១២-០៨-៧៩ | ប្រធានចលនាយុវជនស្រុក | ស្រុកមោងឫស្សី | ស្រុកមោងឫស្សី | ៣ | ៥ | |
| ៧ | សៀម ប៉ាងសុង | ប្រុស | ០៨-១២-៧៧ | ប្រធានចលនាយុវជនឃុំ | ឃុំមោង | ស្រុកមោងឫស្សី | ៤ | ៥ | |
| ៨ | ឡូន វ៉ាន់ឌី | ប្រុស | ០៣-០៥-៨២ | អនុប្រធានចលនាយុវជនស្រុក | ស្រុកឯកភ្នំ | ស្រុកឯកភ្នំ | ៦ | ៦ | |
| ៩ | ឃិន សារឿន | ប្រុស | ០៤-០៤-៨០ | ប្រធានចលនាយុវជនស្រុក | ស្រុកភ្នំព្រឹក | ស្រុកភ្នំព្រឹក | ២ | ៣ | |
| ១០ | រ័ត្ន វុទ្ធី | ប្រុស | ១៩-០៩-៨១ | ប្រធានចលនាយុវជនស្រុក | ស្រុកកំរៀង | ស្រុកកំរៀង | ២ | ៤ | |
| ១១ | ឆួន សុមាលី | ប្រុស | ០៥-០៥-៨២ | សមាជិកចលនាយុវជនស្រុក | ស្រុកមោងឫស្សី | ស្រុកកំរៀង | ៣ | ៤ | |
| ១២ | សែម ពិរស់ | ប្រុស | ០៦-០៣-៧៩ | អនុប្រធានចលនាយុវជនស្រុក | ស្រុកមោងឫស្សី | ស្រុករុក្ខគិរី | ២ | ៣ | ស្រុកថ្មី |
| ១៣ | ផាត់ រិត | ប្រុស | ០២-០៩-៧៩ | អនុប្រធានចលនាយុវជនស្រុក | ស្រុកគាស់ក្រឡ | ស្រុកគាស់ក្រឡ | ៣ | ៣ | |

*✱ បញ្ចប់បញ្ជីត្រឹមលេខរៀងទី ១៣។*

បាត់ដំបង, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩

**ជ.ចលនាយុវជនខេត្តបាត់ដំបង**

**ប្រធាន**

**សួន ចំរើន**

*<u>បញ្ជាក់</u> :*

*-តួលេខរំពឹងជាប់គណនាតាមរយៈចំនួនសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលយើងមាននៅតាមឃុំ-សង្កាត់*

*-យុវជនដែលបានរាយនាមខាងលើសុទ្ធតែរំពឹងថានឹងជាប់ឆ្នោត*